# ការផ្លាស់ប្តូរនៅក្នុងកម្មវិធីហ្វូតស្តែមធ្វើអោយជនអន្តោប្រវេស្តន៍ស្របច្បាប់ជាច្រើន មានសិទ្ធិទទួលជំនួយ

**ខ្ញុំមិនមែនជាពលរដ្ឋមានសញ្ជាតិអាមេរិកាំងទេ ។ តើខ្ញុំអាចទទួលជំនួយហ្វូតស្តែមបានដែរឬទេ ?**

- ***ឥឡូវនេះ***អ្នកអាចមានសិទ្ធិទទួលជំនួយបាន ប្រសិនបើអ្នកមានសិទ្ធិរស់នៅអចិន្ត្រៃស្របច្បាប់ និងប្រសិនបើអ្នក ប្តី ឬ ប្រពន្ធរបស់អ្នក ឬក៏ឪពុកម្តាយរបស់អ្នក មានឯកសារបញ្ជាក់អំពីការងារនៅក្នុងសហរដ្ឋអាមេរិក (ការិយាល័យហ្វូតស្តែម នឹងមានលទ្ធភាពអាចជួយសំរេចបាន ប្រសិនបើអ្នកបានបំរើការងារគ្រប់ចំនួនពេលម៉ោងដែលគេបានតំរូវ) ។ ប្រជាជនដែលមករស់នៅសហរដ្ឋអាមេរិកក្នុងលក្ខណៈជាជនភៀសខ្លួន និងប្រភេទខ្លះផ្សេងទៀតជាជនអន្តោប្រវេស្តន៍អាចមានសិទ្ធិទទួលជំនួយបាន ។ អ្នកក៏អាចនឹងមានសិទ្ធិទទួលបានដែរ ប្រសិនបើអ្នកបានមករស់នៅដោយស្របច្បាប់នៅក្នុងសហរដ្ឋអាមេរិកចាប់តាំងពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៦ ***និង*** (១) អ្នកមានអាយុ ៦៥ ឆ្នាំនៅពេលនោះ (កើតនៅ ឬមុនថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៣១ ***ឬ*** (២) ឥឡូវនេះអ្នកកំពុងទទួលបាននូវប្រាក់ឧបត្ថម្ភសំរាប់ជនពិការ ***ឬក៏*** (៣) ឥឡូវនេះអ្នកមានអាយុក្រោម ១៨ឆ្នាំ ។ អ្នកក៏អាចមានសិទ្ធិទទួលយកជំនួយនេះបានដែរ បើសិនជាអ្នករស់នៅក្នុងសហរដ្ឋអាមេរិកនៅក្នុងលក្ខណៈសម្បត្តិគ្រប់គ្រាន់បានរយៈពេល ៥ឆ្នាំ រួចមកហើយនោះ ។

**តើមានការផ្លាស់ប្តូរអ្វីខ្លះដែលត្រូវបានគេធ្វើឡើងវិញ ?**

- នៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ លោកប្រធានាធិបតី Bush បានចុះហត្ថលេខាលើច្បាប់មួយ គឺច្បាប់ស្តីអំពីសន្តិសុខកសិដ្ឋាន និងការវិនិយោគជនបទសំរាប់ឆ្នាំ ២០០២ (Farm Security and Rural Investment Act of 2002) ដែលនឹងអនុញ្ញាតិអោយអ្នកមិនមានសញ្ជាតិអាមេរិកាំងដែលមានប្រាក់ចំណូលតិចតួច និងជនអន្តោប្រវេស្តន៍ស្របច្បាប់ទទួលបាននូវជំនួយហ្វូតស្តែម ប្រសិនបើពួកគេឆ្លើយតបទៅនឹងតំរូវការធនធាន និងចំណូលរបស់កម្មវិធីហ្វូតស្តែមបាន ។

**តើច្បាប់ថ្មីនេះចាប់អនុវត្តន៍នៅពេលណាដែរ ?**

- ជនអន្តោប្រវេស្តន៍ស្របច្បាប់មួយចំនួនដែលមានលក្ខណៈដូចក្នុងច្បាប់ឆ្នាំ ២០០២ នេះ នឹងអាចមានសិទ្ធិទទួលជំនួយចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០២ នេះតទៅ ប៉ុន្តែជនអន្តោប្រវេស្តន៍ភាគច្រើនទៀត នឹងមិនមានសិទ្ធិទទួលជំនួយរហូតដល់ពេលក្រោយទៀត ។ ពតិមានខាងក្រោមនេះពន្យល់បន្ថែមថានៅពេលណាទើបអ្នកចាប់ផ្តើមមានសិទ្ធិទទួលជំនួយបាន ។

ច្បាប់ឆ្នាំ ២០០២ ផ្តល់សិទ្ធទទួលជំនួយដល់ជនអន្តោប្រវេស្តន៍ស្របច្បាប់ទាំងឡាយណាដែលឆ្លើយតបទៅនឹងតំរូវការរបស់កម្មវិធី **និង**អ្នកដែល :

✔ កំពុងទទួលជំនួយជាជនពិការ (ដូចជាជំនួយ SSI ឬជំនួយសុខភាពសំរាប់ជនពិការ) (អ្នកទាំងនេះមានសិទ្ធិទទួលជំនួយពីថ្ងៃទី **១ តុលា ឆ្នាំ ២០០២** នេះតទៅ)

✔ បានរស់នៅក្នុងសហរដ្ឋអាមេរិកអស់រយៈពេល ៥ ឆ្នាំ ក្នុងលក្ខណៈសម្បត្តិគ្រប់គ្រាន់ (អ្នកទាំងនេះមានសិទ្ធិទទួលជំនួយពីថ្ងៃទី **១ ខែ មេសា ឆ្នាំ ២០០៣**) ឬ

✔ មានអាយុក្រោម ១៨ ឆ្នាំ និង បានចូលទៅរស់នៅក្នុងសហរដ្ឋអាមេរិកក្រោយថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៦ (អ្នកទាំងនេះមានសិទ្ធិទទួលចាប់ពីថ្ងៃទី **១ ខែ តុលា ឆ្នាំ ២០០៣** នេះតទៅហើយ) ។

**តើជនអន្តោប្រវេស្តន៍ណាទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះ ?**

- ជនអន្តោប្រវេស្តន៍ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមមានអ្នកដែលមានទីលំនៅអចិន្ត្រៃយ៍ (កាន់កាតបៃតង) ជនភៀសខ្លួន ជនសុំសិទ្ធិជ្រកកោន ប្រជាជនដែលត្រូវបានជំទាស់ក្នុងការនិរទេស ឬផ្លាស់ប្តូរទីលំនៅ អ្នកមានសញ្ជាតិគុយបា ហៃទី បុគ្គលទាំងឡាយណាដែលបានទទួលជាលក្ខណៈប៉ារ៉ូលីពីកិច្ចបំរើអន្តោប្រវេសន៍ និងសញ្ជាតូបនីយកម្ម (Immigration and Naturalization Service-INS) នៅក្នុងសហរដ្ឋអាមេរិករយៈពេលយ៉ាងតិចបំផុតមួយឆ្នាំ អ្នកចូលមករស់នៅដោយមានលក្ខខ័ណ្ឌ និង ជនរងគ្រោះដោយអំពើហឹង្សានៅក្នុងគ្រួសារ ។

**តើការផ្លាស់ប្តូរច្បាប់នេះ ប៉ះពាល់ទៅដល់ជនអន្តោប្រវេស្តន៍ដែលមានសិទ្ធិទទួលជំនួយរួចហើយបានដែរឬទេ?**

- ទេ ។ ជនណាដែលមានសិទ្ធិទទួលជំនួយកាលពីមុន នឹងនៅបន្តទទួលជំនួយរហូតដល់ពេលឥឡូវនេះ ។

**តើច្បាប់នេះ ផ្តល់សិទ្ធិដល់អ្នកមិនមានសញ្ជាតិអាមេរិកាំង ដែលរស់នៅក្នុងប្រទេសដោយសារហេតុផលមនុស្សធម៌ ឱ្យបានទទួលជំនួយនេះដែរឬទេ ?**

- បាន ។ ជាលទ្ធផលច្បាប់ឆ្នាំ ២០០២ វានឹងឈប់កំណត់ការទទួលជំនួយរយៈពេល ៧ ឆ្នាំសំរាប់អ្នកទទួលជំនួយហ្វូតស្តែមតទៅទៀតហើយសំរាប់ជនភៀសខ្លួន អ្នកសុំសិទ្ធិជ្រកកោន ជនជាតិអាស៊ី-អាមេរិកកាំង និងអ្នកចូលសញ្ជាតិគុយបា ឬហៃទី ។ ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៣ នេះ អ្នកដែលមិនមានសញ្ជាតិអាមេរិកាំងទាំងនេះ គឺមានសិទ្ធិទទួលជំនួយបាន ដ៏រាបណាគេមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមតំរូវការនៃកម្មវិធីដោយផ្អែកលើប្រាក់ចំណូល និង ធនធាន ។

**តើកម្មវិធីហ្វូតស្តែមនឹងសំរេចផ្តល់ជំនួយអោយទេ ប្រសិនបើខ្ញុំជាមនុស្សពិការ ?**

- ទេ ។ អ្នកត្រូវតែទទួលជំនួយ ឬក៏ការឧបត្ថម្ភមួយពីកម្មវិធី ដូចជាជំនួយផ្អែកពេទ្យ ពីព្រោះអ្នកពិការភ្នែក ឬជាជនពិការ ។

**តើខ្ញុំអាចទទួលជំនួយជំនួសកូនរបស់ខ្ញុំដែលមានសញ្ជាតិអាមេរិកាំងបានដែរឬទេ ក្នុងករណីបើខ្ញុំមិនមែនជាជនអន្តោប្រវេស្តន៍ ដែលមានសិទ្ធិទទួលជំនួយបាន ?**

- បាន ។ អ្នកនឹងមិនចាំបាច់ផ្តល់ឯកសារផ្សេងៗអំពីខ្លួនអ្នកផ្ទាល់ទេ នៅពេលណាដែលអ្នកដាក់ពាក្យសុំអោយកូនរបស់អ្នក ឬមនុស្សណាផ្សេងទៀតនៅក្នុងគ្រួសាររបស់អ្នកដែលមានសិទ្ធិទទួល ។ ទោះជាយ៉ាងនេះក្តី អ្នកនឹងនៅតែត្រូវបង្ហាញនូវភស្តុតាងអំពីប្រាក់ចំណូល និងធនធានរបស់អ្នក ដើម្បីអោយអ្នកកាន់សំណុំរឿងកំណត់បាននូវបរិមាណជំនួយសំរាប់ផ្តល់ជូនអ្នកទាំងនោះ ។

**តើការទទួលយកហ្វូតស្តែមធ្វើអោយខ្ញុំខូចប្រយោជន៍ដែរឬទេ ប្រសិនបើខ្ញុំចង់ចូលជាសញ្ជាតិអាមេរិកាំងនោះ ?**

- មិនទេ ។ ការទទួលយកជំនួយហ្វូតស្តែមមិនធ្វើអោយជនអន្តោប្រវេស្តន៍ជាប់ឈ្មោះចោទប្រកាន់ជាសាធារណៈនោះឡើយ – វាមានន័យថា ជនអន្តោប្រវេស្តន៍ដែលទៅរស់នៅសហរដ្ឋអាមេរិកនឹងមិនត្រូវបានគេនិរទេសចេញ បដិសេធមិនអោយចូលក្នុងប្រទេស ឬបដិសេធមិនផ្តល់ឱ្យនូវលំនៅអចិន្ត្រៃយ៍ ឬក៏ បដិសេធមិនផ្តល់ប័ណ្ណពិណបៃតងអោយ ដោយសារតែអ្នកនោះទទួលជំនួយហ្វូតស្តែមនោះទេ ។

**តើខ្ញុំអាចដាក់ពាក្យសុំជំនួយ ឬចង់ដឹងបន្ថែមទៀតបានដោយរបៀបណា ?**

- ដើម្បីទទួលជំនួយហ្វូតស្តែម អ្នកត្រូវទៅដាក់ពាក្យសុំនៅឯការិយាល័យហ្វូតស្តែមនៅក្នុងតំបន់របស់អ្នក ដែលតាមធម្មតាវាស្ថិតនៅជាមួយការិយាល័យវែលហ្វែរក្នុងតំបន់ ។
- ដើម្បីទទួលបាននូវពតិមានបន្ថែម សូមទូរស័ព្ទទៅការិយាល័យហ្វូតស្តែមនៅក្នុងតំបន់របស់អ្នក ដែលវាមានចុះបញ្ជីនៅក្នុងសៀវភៅទូរស័ព្ទផ្នែកពិណខៀវ ដែលស្ថិតនៅក្រោមក្រសួងសង្គមកិច្ច (Social Services Department) ឬ ក្រសួងវែលហ្វែរ (Welfare Department) ឬក៏ទូរស័ព្ទទៅកាន់លេខដែលឥតគិតថ្លៃគឺ **1-800-221-5689** ។
- ពិតមាន និងការបំរើជាភាសាអេស្ប៉ាញមានផ្តល់ជូនអ្នកតាមលេខទូរស័ព្ទដែលឥតគិតថ្លៃនេះដែរ ។

***ហ្វូតស្តែមធ្វើឱ្យអាមេរិកកាន់តែខ្លាំងឡើង ។***

*ក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (United States Department of Agriculture - USDA) គឺជាអ្នកផ្តល់ និង កន្លែងឱ្យឱកាសស្មើភាពគ្នា ។*